**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៦៩)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៣ ៣៩៨នាក់ នៃរោងចក្រ សហគ្រាសទាំង៤២ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាសទាំង៤២ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

*ថ្ងៃចន្ទ ៧កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*

*រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២១*

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

### ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១

### បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ចំនួន ៤២ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 3 |
| 1 | ក្រុមហ៊ុន អៅវើចិចស្តាយកូលិកសិន ខូអិលធីឌី | ភ្នំពេញ |
| 2 | ក្រុមហ៊ុន សាប ភ្នំពេញ ឯ.ក | ភ្នំពេញ |
| 3 | ក្រុមហ៊ុន តេហ្វ៊ូអាំប្រេឡឺ ស្រុកព្រៃឈរ ខេត្តកំពង់ចាម | កំពង់ចាម |
| ខ. វិស័យទេសចរណ៍ | | 39 |
| 4 | ក្រុមហ៊ុន បាអាតហ្គត ឯ.ក | ភ្នំពេញ |
| 5 | ក្រុមហ៊ុន អិល&អិម បាសាក់ រីវើរ ខូ អិលធីឌី | ភ្នំពេញ |
| 6 | សណ្ឋាគារភ្នំពេញអេរ៉ា | ភ្នំពេញ |
| 7 | សណ្ឋាគារ អូឡាំព្យា ស៊ីធី ហូថេល | ភ្នំពេញ |
| 8 | សណ្ឋាគារ ហ្គាឌិន ស៊ីធី ហូថេល | ភ្នំពេញ |
| 9 | ក្រុមហ៊ុន ស្កាយ យើង ត្រាវែល & ធួរ | ភ្នំពេញ |
| 10 | ក្រុមហ៊ុន ភីអេស សហការ ឯ.ក | ភ្នំពេញ |
| 11 | ក្រុមហ៊ុន ឡឺ ប្រេស៊ីដង់អូតែល-កូបេ | ភ្នំពេញ |
| 12 | ក្រុមហ៊ុន វើលដ៏ ដាយនីង លីមីធីត | ភ្នំពេញ |
| 13 | ក្រុមហ៊ុន ម៉ាស្ទ័រស៊ុគីស៊ុប | ភ្នំពេញ |
| 14 | ក្រុមហ៊ុន ដារ៉ា អ៊ែរផត ហូថេល | ភ្នំពេញ |
| 15 | សណ្ឋាគារ រ៉េស៊ីដង់ សុខាភ្នំពេញ | ភ្នំពេញ |
| 16 | ក្រុមហ៊ុន ថាឡាស | ភ្នំពេញ |

| ល.រ | ឈ្មោះពេទចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 17 | ក្រុមហ៊ុន វីណា ហុងកុង ខំផែនី អែលធីឌី | ភ្នំពេញ |
| 18 | សណ្ឋាគារវិត្តូរីយ៉ាអង្គរ រីសត និង ស្ប៉ា | សៀមរាប |
| 19 | ក្រុមហ៊ុន អង្គរ ហូលីដេ | សៀមរាប |
| 20 | សណ្ឋាគារ អង្គរ ហូតែល គ្រុប(សណ្ឋាគារ អប្សរា ផាឡេស) | សៀមរាប |
| 21 | ក្រុមហ៊ុន ភូមិបៃតង (ខេមបូឌា) | សៀមរាប |
| 22 | សណ្ឋាគារ ស្វាយលីង | សៀមរាប |
| 23 | សណ្ឋាគារខេមរាអង្គរ | សៀមរាប |
| 24 | សណ្ឋាគារជីឡាពេ (ផាកហៃយ៉ាត់សៀមរាប) | សៀមរាប |
| 25 | សណ្ឋាគារសុខាសៀមរាប | សៀមរាប |
| 26 | សណ្ឋាគារ សុខាអង្គរ | សៀមរាប |
| 27 | ក្រុមហ៊ុន ហាប់ ហេង អ៊ីនវេសមេន ភីធីអ៊ី អិលធីឌី | សៀមរាប |
| 28 | ក្រុមហ៊ុន ហ្វូខឹស អេស៊ា អ៊ីនធើណេសិនណលត្រាវែល សឺវីស | សៀមរាប |
| 29 | ក្រុមហ៊ុន GB II Co., LTD | សៀមរាប |
| 30 | ក្រុមហ៊ុន ខមហ្វូតប្រធីធី សឺលូសិន (ខូអិល ធីឌី) | សៀមរាប |
| 31 | ក្រុមហ៊ុន បា ឡឺ កូដ ត្រេឌីង | សៀមរាប |
| 32 | ផ្ទះសំណាក់ សាតូអង្គ | សៀមរាប |
| 33 | ផ្ទះសំណាក់ ហនុមានាល័យ | សៀមរាប |
| 34 | ភោជនីយដ្ឋានសុខៈវីរើរីវើឡោញ | សៀមរាប |
| 35 | ក្រុមហ៊ុន ម៉ុនស៊ូន អេស៊ាន ប៊ីស្ត្រូ | សៀមរាប |
| 36 | សណ្ឋាគារសុខៈប៊ូទិក | សៀមរាប |
| 37 | ក្រុមហ៊ុន តារារង្សី អង្គរ ហូថេល | សៀមរាប |
| 38 | ក្រុមហ៊ុន ព្រីនសៅ វីហ្សេត (អាម៉ាន់សារា) | សៀមរាប |
| 39 | សណ្ឋាគារ រស្មី ចន្ទ័រះ | សៀមរាប |
| 40 | សណ្ឋាគារ អង្គរ ភើល | សៀមរាប |
| 41 | សណ្ឋាគារសោមាទេវីអង្គររីសត & ស្ប៉ា | សៀមរាប |
| 42 | រមណីយដ្ឋានឆ្នេរសុខា | ព្រះសីហនុ |